ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណាននីង

លេខ ០០28 កពណក.ណន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ : របាយការណ៍ខែឧសភា ឆ្នាំ២០១១**

ខ្ញុំបាទមានកិត្តិយសគោរពជូនឯកឧត្តម **ទេសរដ្ឋមន្ត្រី** នូវរបាយការណ៍ប្រចាំខែឧសភា របស់ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា ប្រចាំក្រុងណាននីង ដូចតទៅ :

**១ ការងារទំនាក់ទំនងភ្ញៀវ :**

-ជួបក្រុមហ៊ុន Gold Wood Group មានគំរោងវិនិយោគនៅកម្ពុជា លើការកែច្នៃដើមស្រល់ ដើម្បីបំរើ ឱ្យវិស័យឧស្សាហកម្ម ។ ក្រុមហ៊ុនបានចុះទៅស្រាវជ្រាវនៅកម្ពុជារួចហើយ ។

-ជួប លោកជំទាវឯកអគ្គរាជទូត ដើម្បីសំដែងការគួរសម ។

-ជួបលេខាធិការដ្ឋាន China–ASEAN Expo និងជួបមន្ទីរពាណិជ្ជកម្មតំបន់ស្វយ័តខេត្តក្វាងស៊ី ដើម្បីទំនាក់ទំនង និងសំដែងការគួរសម ។

-ជួបក្រុមហ៊ុន KAMA Diesel Engine Co.,Ltd មានបំណងស្វែងរកដៃគូ ដើម្បីលក់គ្រឿងម៉ាស៊ីន គ្រឿងយន្តនៅកម្ពុជា ។

-ជួបក្រុមហ៊ុន Guangxi Maofu Potato Co.,Ltd និងក្រុមហ៊ុន Guangxi Diligent Farming Co.,Ltd មានបំណងបើកកសិដ្ឋានដាំដំឡូងបារាំងនៅកម្ពុជា ដោយប្រើប្រាសបច្ចេកទេសទំនើបមានគុណភាពខ្ពស់ ។

-ទៅទស្សនាកសិដ្ឋានដាំបន្លែ Zhongcai Shunming agriculture Science and Technology Co.,Ltd មានបំណងបើកកសិដ្ឋានដាំបន្លែតាមបច្ចេកទេសទំនើប ដែលមានទិន្នផលខ្ពស់នៅកម្ពុជា ។

-ជួប Investment Promotion Bureau of Nanning មានបំណងទៅកម្ពុជា ដើម្បីជួបថ្នាក់ដឹកនាំក្រសួង ពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងសមាគមពាណិជ្ជកម្មមួយចំនួន ។ អង្គភាពនេះមានបំណងបើកសិក្ខាសាលាមួយនៅកម្ពុជា ដោយអញ្ជើញសមាគមពាណិជ្ជកម្មចំនួន២៥នាក់មកចូលរួម ដែលគ្រោងធ្វើនៅភ្នំពេញនៅដំណាច់ខែមិថុនាខាងមុខនេះ ។

## ២ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មរវាងកម្ពុជា_ក្វាងស៊ី

កិច្ចសហប្រតិបត្តិការជាដៃគូរវាងកម្ពុជា-ចិន បានអនុវត្តចាប់តាំងពីឆ្នាំ២០០៦មកម្ល៉េះ ក្រោយពីកសាងតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ថ្នាក់ដឹកនាំខេត្តក្វាងស៊ីនិងកម្ពុជាបានទំនាក់ទំនងកាន់តែល្អឡើង លើវិស័យវប្បធម៌ សង្គមនិងសេដ្ឋកិច្ច ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៨-២០០៩ ថ្នាក់ដឹកនាំខេត្តក្វាងស៊ីបានទៅបំពេញទស្សនកិច្ចនៅកម្ពុជា ។ កិច្ចសហប្រតិបត្តិការសំខាន់មួយទៀត គឺកម្ពុជាបានចូលរួមតាំងពិព័រណ៍ចិន-អាស៊ានជារៀងរាល់ឆ្នាំ ។ឆ្លងតាមរយៈពិព័រណ៍ខាងលើ គេសង្កេតឃើញថា ដំណើរនៃការចុះកិច្ចសន្យា ផ្លាស់ប្តូរពាណិជ្ជកម្មកម្ពុជា-ចិន មានការកើនឡើងខ្ពស់គួរឱ្យកត់សំគាល់ ។

## ៣ ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងកម្ពុជា_ខេត្តក្វាងស៊ី

នៅក្នុងឆ្នាំ២០១០ ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងកម្ពុជានិងខេត្តក្វាងស៊ី សំរេចបាន ៩.៤៤លានដុល្លាសហរដ្ឋអាមេរិក បានកើន១៤% បើប្រៀបធៀប ជាមួយឆ្នាំ២០០៩ កន្លងមក ។ ខេត្តក្វាងស៊ីបាននាំចេញមកកម្ពុជា ដែលមានទឹកប្រាក់៨.៣៨លានដុល្លាសហរដ្ឋអាមេរិក និងបាននាំចូលពីកម្ពុជាចំនួន១.០៦លានដុល្លាសហរដ្ឋអាមេរិក ។ ផលិតផលដែលខេត្តក្វាងស៊ីនាំចេញទៅកម្ពុជា មានផលិតផលតម្បាញ គ្រឿង យន្ត អេឡិចត្រូនិច អសន្ឋាណូ និងផលិតផលគីមី ឯការនាំចូលពីកម្ពុជាវិញ មានផលិតផលកសិកម្ម ។

## ៤ ការទាញវិនិយោគ

រហូតមកដល់ដំណាច់ឆ្នាំ២០១០ ខេត្តក្វាងស៊ីបានមកវិនិយោគទុននៅកម្ពុជា ដែលមានទឹកប្រាក់៥០.៩៥លានដុល្លាសហរដ្ឋអាមេរិក លើវិស័យសំខាន់ៗមួយចំនួន មានវិស័យរ៉ែ ពាណិជ្ជកម្ម កសិកម្ម គីមីឧស្សាហកម្ម និងឧស្សាហកម្មធុនស្រាលជាដើម ។ គិតរហូតមកដល់ដំណាច់ឆ្នាំ២០១០ ខេត្តក្វាងស៊ីបានចុះកិច្ចសន្យាឧស្សាហកម្មជាមួយកម្ពុជា ដែលមានទឹកប្រាក់សរុប២៩.៥៨លានដុល្លាសហរដ្ឋអាមេរិក ។ ជាក់ស្តែងអនុវត្តបានតែ១៩.៧៤លានដុល្លាសហរដ្ឋអាមេរិក ។ ក្រុមហ៊ុនខេត្តក្វាងស៊ីមកវិនិយោគនៅកម្ពុជាមានក្រុមហ៊ុន :

- Huazi Shiye Cambodia Co.,Ltd ដែលមានទឹកប្រាក់១.៥លានដុល្លាសហរដ្ឋអាមេរិក ។
- ក្រុមហ៊ុន Guangxi Nonferrous Metals Group Co.,Ltd ដែលមានទឹកប្រាក់២៩.៨លានដុល្លាសហរដ្ឋអាមេរិក ។
- ក្រុមហ៊ុនDongxing City, Jinghua Industry Co.,Ltd ដែលមានទឹកប្រាក់៥.៧លានដុល្លាសហរដ្ឋអាមេរិក ។
- ក្រុមហ៊ុន Guangxi German Motor Transports Group Co.,Ltd ដែលមានទឹកប្រាក់០.៥លានដុល្លាសហរដ្ឋអាមេរិក ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម **នាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែឧសភា ដោយអនុគ្រោះបំផុត ។ សូមឯកឧត្តម **នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ណាននីង ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១

ទីប្រឹក្សាពាណិជ្ជកម្ម

**អ៊ុច គីមយ៉ុន**

ចម្លងជូន

- អគ្គកុងស៊ុលប្រចាំក្រុងណាននីង
- ឯកសារនិងកាលប្បវត្តិ

Add : #11Zhujin Road,China-ASEAN Business District,Nanning, Guangxi ,China Email: clo_cambodia@yahoo.com Tel/Fax: (0771)5389496